**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជានៅព្រះសហគមន៍សន្តសិលា**
**ពោធិ៍ធំ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២០**

# ឲ្យយើងមានលក្ខណៈដូចព្រះបិតា

**អត្ថបទទី១៖ លេវីវិន័យ ១៩,១-២.១៧-១៨**

កុំសងសឹកឲ្យសោះ ហើយក៏មិនត្រូវចងគំនុំនឹងជនរួមឈាមរបស់អ្នកដែរ ចូរស្រឡាញ់អ្នកដទៃឲ្យបានដូចស្រឡាញ់ខ្លួនឯង យើងជាព្រះអម្ចាស់។ លវ ១៩,១៨

**អត្ថបទទី២៖ កូរិនថូសទី១ ៣,១៦-២៣**

សូមកុំបញ្ឆោតខ្លួនឯងឲ្យសោះ ប្រសិនបើមាននរណាម្នាក់ក្នុងចំណោមបងប្អូននឹកស្មានថាខ្លួនជាអ្នកប្រាជ្ញតាមរបៀបលោកីយ៍នេះ អ្នកនោះត្រូវតែធ្វើជាមនុស្សលីលាកសិន ដើម្បីឲ្យបានទៅជាអ្នកប្រាជ្ញ។ ១ករ ៣,១៨

**ដំណឹងល្អ៖ ម៉ាថាយ ៥,៣៨-៤៨**

បើអ្នករាល់គ្នារាប់រកតែបងប្អូនរបស់ខ្លួនប៉ុណ្ណោះ តើមានអ្វីអស្ចារ្យ? សូម្បីតែសាសន៍ដទៃក៏ប្រព្រឹត្តដូច្នោះដែរ។ មថ ៥,៤៧

បងប្អូនជាទីស្រឡាញ់!

ពេលយើងស្ដាប់គម្ពីរដំណឹងល្អថ្ងៃនេះ ណែនាំឲ្យយើងបារម្ភ យើងធ្វើដូចម្ដេចដើម្បីអនុវត្តអ្វីដែលព្រះយេស៊ូមានព្រះបន្ទូល។ ជាពិសេស ព្រះបន្ទូលចុងក្រោយដែលថា "**ព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខគ្រប់លក្ខណៈយ៉ាងណា សូមឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណៈយ៉ាងនោះដែរ**" មានន័យថាព្រះបិតាជាសេចក្ដីស្រឡាញ់ ឲ្យយើងទៅជាសេចក្ដីស្រឡាញ់ដែរ ព្រះបិតាលើកលែងទោសឲ្យយើងជានិច្ច ឲ្យយើងលើកលែងទោសឲ្យគេជានិច្ចដែរ ព្រះបិតាស្រឡាញ់មនុស្សទាំងឡាយដោយមានព្រះហឫទ័យប្រណីសន្ដោស ឲ្យយើងស្រឡាញ់មនុស្សទាំងអស់ដោយបង្ហាញធម៌មេត្តាករុណាដូចព្រះបិតាដែរ...។ យើងមើលព្រះបិតាជាព្រះជាម្ចាស់ព្រះយេស៊ូអញ្ជើញយើងទាំងអស់ដែលជាមនុស្សធម្មតា ឲ្យយើងរស់នៅតាមរបៀបព្រះបិតា មានន័យថានៅពេលបងប្អូនឯទៀតៗជួបយើងដែលជាគ្រីស្ដបរិស័ទ ឲ្យគេមើលឃើញព្រះជាម្ចាស់ដែលនៅស្ថានបរមសុខ។ យើងជាមនុស្សដែលមានអំពើបាប តែយើងមានគំរូមួយយ៉ាងពិសេសគឺព្រះបិតាផ្ទាល់ យើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងណែនាំឲ្យយើងចូលបន្តិចម្ដងៗនៅក្នុងជីវិតថ្មី។ នេះជាអ្វីដែលព្រះយេស៊ូបានទេសនាទៅសាវ័កនិងមហាជន ឲ្យយើងចាប់ផ្ដើមចូលនៅក្នុងរបៀបថ្មី។

ពីមុនពេលគេវាយយើងយើងវាងគេវិញ គេធ្វើអាក្រក់ដល់យើងធ្វើអាក្រក់ដាក់គេវិញ ប៉ុន្តែព្រះយេស៊ូមានរបៀបថ្មី នៅពេលគេវាយយើងខាងស្តាំយើងទុកឲ្យគេវាយខាងឆ្វេងមួយទៀត នៅពេលគេធ្វើបាបដល់យើងឲ្យយើងឯកភាពឲ្យគេធ្វើបាបយើងមួយទៀត។ ព្រះយេស៊ូចង់បង្ហាញថាចាប់ពីពេលនេះតទៅយើងមានជីវិតថ្មី ដោយណែនាំឲ្យយើងខិតខំអស់ពីសមត្ថភាពរបស់យើងនៅពេលគេប្រើហិង្សាដល់យើងកុំឲ្យយើងឆ្លើយតបដោយប្រើហិង្សាដាក់គេវិញ តែឲ្យយើងបង្កើតសេចក្តីសុខសាន្ត។ ព្រះយេស៊ូ បានឲ្យវិន័យថ្មីដល់យើងគឺ ឲ្យយើងស្រឡាញ់បងប្អូនឯទៀតៗនិងស្រឡាញ់ខ្មាំងសត្រូវរបស់យើងដែរ ដោយអធិដ្ឋានសម្រាប់គេថែមទៀត។ យើងទាំងអស់គ្នាយើងមានសត្រូវ ពិបាកណាស់ដែលឲ្យយើងស្រឡាញ់សត្រូវ មនុស្សដែលស្អប់យើង មនុស្សដែលណែនាំឲ្យយើងឈឺចាប់យើងពិបាកណាស់ដែលមកស្រឡាញ់គេ។ ប៉ុន្តែថ្ងៃនេះ ព្រះយេស៊ូបានណែនាំឲ្យយើងចូលនៅក្នុងសេចក្តីស្រឡាញ់ពិសេសរបស់ព្រះជាម្ចាស់ គឺ **"ស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ដូចព្រះជាម្ចាស់ស្រឡាញ់អ្នករាល់គ្នាដែរ"**។ ប្រសិនបើ យើងសម្លឹងមើលព្រះយេស៊ូនៅលើឈើឆ្កាង ពេលគេឆ្កាងព្រះអង្គព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូគឺ **"សូមលើកលែងទោសឲ្យគេ ព្រោះគេមិនដឹងអ្វីដែលគេកំពុងធ្វើ"**។

យើងមានគំរូមួយពិសេស ព្រះបិតានៅស្ថានបរមសុខយើងមើលមិនឃើញ ប៉ុន្តែជីវិតរបស់ព្រះយេស៊ូយើងមើលឃើញផ្ទាល់។ យើងដឹងអំពីអ្វីដែលព្រះយេស៊ូបានធ្វើ ជាមួយអ្នកក្រីក្រជាមួយអ្នកតូចតាច ជាមួយអ្នកទារពន្ធ ជាមួយអ្នកជំងឺ... ពេលយើងមើលឃើញរបៀបព្រះយេស៊ូណែនាំឲ្យយើងមើលឃើញរបៀបព្រះបិតាដែរ។ ពេលយើងមើលឃើញរបៀបព្រះយេស៊ូ យើងមានគំរូមួយយ៉ាងពិសេសសម្រាប់ជីវិតរបស់យើងផ្ទាល់។ ខ្ញុំសូមចែករំលែកបួនចំណុច ដែលសម្តេចប៉ាបប្រាំង់ស៊ីស្កូ បានផ្ញើជូនព្រះសហគមន៍ទាំងមូល ដើម្បីមានសេចក្តីស្រឡាញ់ដូចព្រះបិតាដើម្បីមានលក្ខណៈដូចព្រះបិតា គឺ៖

**ទីមួយ ឲ្យយើងយកចិត្តទុកដាក់បម្រើអ្នកក្រីក្រ** ជាពិសេសណែនាំឲ្យអ្នកក្រីក្រមានសិទ្ធិដូចគេឯង កុំឲ្យយើងមានសង្គមដែលបែងចែកមនុស្សមានពីរប្រភេទ។ អ្នកមានមានសិទ្ធិធ្វើអ្វីៗទាំងអស់បាន អ្នកដែលក្រីក្រគ្មានសិទ្ធិអ្វីសោះ ឲ្យសិទ្ធិមនុស្សមានស្មើគ្នាសម្រាប់មនុស្សទាំងអស់។ នៅក្នុងជីវិតរបស់យើង ឲ្យមនុស្សទាំងអស់យល់ថាជីវិតរបស់យើងមានតម្លៃថ្លៃថ្នូរយ៉ាងពិតប្រាកដ។ ទោះបីព្រះសហគមន៍យើងតូចក៏ដោយ នៅពេលយើងលើកទឹកចិត្តជាមួយអ្នកក្រីក្រ ជាមួយកម្មករ ជាមួយអ្នកជំងឺ ជាមួយបងប្អូនដែលសង្គមមិនអើពើ យើងដឹងថានៅពេលនោះយើងចូលនៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ មានន័យថា យើងបានធ្វើដំណើរជាមួយអ្នកក្រីក្រដើម្បីឲ្យមនុស្សទាំងអស់មានជីវិតថ្លៃថ្នូរ និងមានសិទ្ធិស្មើៗគ្នា នេះជាសម្លេងដែលព្រះ

សហគមន៍អាចមាន។ សម្លេងនេះមិនមែនដោយសារយើងប្រកាស ឬស្រែក តែជាសម្លេងដែលយើងយកចិត្តទុកដាក់បម្រើពីមួយថ្ងៃទៅមួយ។ នៅក្នុងរដូវ៤០ថ្ងៃខាងមុខនេះ យើងជាព្រះសហគមន៍ យើងមានសញ្ញាអ្វីខ្លះដើម្បីបម្រើអ្នកក្រីក្រមួយចំនួន ដើម្បីលើកទឹកចិត្តបងប្អូនដែលគ្មានសេចក្តីសង្ឃឹម ដើម្បីធ្វើដំណើរជាមួយមនុស្សដែលបាត់បង់តម្លៃថ្លៃថ្នូរនៅក្នុងជីវិត។

**ទីពីរ ឲ្យយើងទទួលស្គាល់អំពីវប្បធម៌ អំពីអរិយធម៌ អំពីប្រពៃណីនៃប្រទេសនីមួយៗ** ជាពិសេសនៅប្រទេសកម្ពុជាឲ្យយើងយល់យ៉ាងច្បាស់អំពីវប្បធម៌នៃប្រទេសយើង។ អំពីរបៀបដែលប្រទេសយើងគោរពសាសនា គោរពបងប្អូនឯទៀតៗ ស្រឡាញ់គ្រួសារ គោរពបុណ្យប្រពៃណីជាតិ ឲ្យយើងយល់អំពីសាសនា វប្បធម៌ ប្រពៃណី ដើម្បីឲ្យយើងរួមគ្នាយើងដឹងថាព្រះសហគមន៍របស់យើងមិនមែនជាព្រះសហគមន៍របស់សាសន៍ដទៃដែលមកពីបរទេស។ ព្រះសហគមន៍របស់យើង ជាព្រះសហគមន៍ដែលភ្ជាប់នឹងជីវិត អំណរសប្បាយ ទុក្ខលំបាក ប្រពៃណីវប្បធម៌ សាសនា របៀបដែលប្រជាជនកម្ពុជារស់នៅជាប្រចាំ ដើម្បីឲ្យព្រះហឫទ័យរបស់ព្រះគ្រីស្តចូលនៅក្នុងទឹកដីរបស់យើងយ៉ាងជ្រៅ និងធ្វើដំណើរជាមួយបងប្អូនយ៉ាងពិតប្រាកដ។ របៀបដែលយើងអធិដ្ឋាន របៀបដែលយើងបង្កើតទំនាក់ទំនង របៀបដែលយើងចូលនៅក្នុងបុណ្យប្រពៃណីនីមួយៗ... នេះជារបៀបដែលបង្ហាញថាយើងជាគ្រួសារតែមួយដែលចេះគោរពគ្នាទៅវិញទៅមក ដែលចេះទទួលប្រពៃណី អរិយធម៌ វប្បធម៌ ដ៏អស្ចារ្យដើម្បីចូលនៅក្នុងពន្លឺរបស់ព្រះគ្រីស្តផង។

**ទីបី ឲ្យយើងស្រឡាញ់និងថែរក្សាធម្មជាតិរបស់យើង** ព្រះជាម្ចាស់បានប្រទានអ្វីៗទាំងអស់ ប្រសិនបើយើងមិនចេះថែរក្សាយូរៗយើងអស់ទាំងអស់។ ពេលយើងអស់ព្រៃឈើ ពេលយើងអស់សត្វ យើងគ្មានអ្វីដើម្បីចិញ្ចឹមជីវិតរបស់យើងទៀតទេ ឲ្យយើងស្រឡាញ់ធម្មជាតិរបស់យើង។ សព្វថ្ងៃ នៅក្នុងទន្លេយើងនេសាទបានត្រីតិចទៅៗ នេះដោយសារលទ្ធផលនៃរបៀបដែលយើងរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដែលណែនាំឲ្យយើងបំផ្លាញធម្មជាតិ។ យើងធ្វើយ៉ាងណា ថែរក្សាធម្មជាតិដែលព្រះជាម្ចាស់បានប្រទាន ដើម្បីរស់នៅយ៉ាងសុខដមរមនារវាងយើងជាមនុស្សធម្មជាតិ អាកាសធាតុ អ្វីៗទាំងអស់ដែលព្រះជាម្ចាស់ប្រទានដើម្បីបង្ហាញថាផែនដីជាផ្ទះផ្ទាល់របស់យើង មនុស្សយើងជាក្រុមគ្រួសារមួយដែលចេះស្រឡាញ់ផ្ទះរបស់យើងយ៉ាងពិតប្រាកដមែន។

**ទីបួន ធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍នីមួយៗ សហគមន៍នីមួយៗរស់នៅនៅក្នុងរបៀបថ្មី។** ជួនកាលយើងខ្វះបូជាចារ្យខ្វះបងប្រុសបងស្រី ប៉ុន្មានឆ្នាំទៀតប្រសិនបើយុវជនយុវនារីមិនភ្ញាក់ស្មារតីស្តាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ យើងនៅបន្តខ្វះលោកបូជាចារ្យ ខ្វះបងប្រុស

បងស្រី ដើម្បីបម្រើព្រះសហគមន៍យើងដដែល។ សម្តេចប៉ាបជម្រុញ ឲ្យយុវជនយុវនារីយកចិត្តទុកដាក់បម្រើព្រះសហគមន៍ផ្ទាល់ខ្លួនយ៉ាងច្បាស់លាស់។

ឆ្នាំនេះ យើងមានរយៈពេល៣០ឆ្នាំហើយដែលយើងបានបង្កើតព្រះសហគមន៍សាជាថ្មីជាមួយលោកអភិបាល អ៊ីវ លោក អេមីល នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩០ ដែលយើងបានថ្វាយអភិបូជាសាជាថ្មី។ យើងបានទុកអាទិភាពបីដើម្បីទៅមុខបាន **គឺឲ្យយើងមានក្រុមសង្គហៈមេត្តាករុណា** ដែលបង្ហាញមេត្តាករុណាដល់អ្នកក្រីក្រ **ឲ្យយើងមានក្រុមពិធីបុណ្យ** ដែលយកចិត្តទុកដាក់រៀចំការអធិដ្ឋាន រៀបចំព្រះវិហារ រៀបចំកន្លែងសក្ការៈដើម្បីថ្វាយបង្គំនិងបង្ហាញសេចក្តីស្រឡាញ់ដល់ព្រះជាម្ចាស់ និង**ឲ្យយើងមានក្រុមអប់រំជំនឿ** កុំឲ្យយើងបាត់បង់ជំនឿ យើងមានគ្រូអប់រំជំនឿដែលបានអប់រំបន្ត។ នេះជារបៀបដែលយើងបានបង្កើតព្រះសហគមន៍ ដោយណែនាំឲ្យគ្រីស្តបរិស័ទទទួលខុសត្រូវយ៉ាងពេញលក្ខណៈ។ ពេលយើងមានកម្មវិធីនៅក្នុងភូមិភាគ ឲ្យយើងចូលរួមយ៉ាងសកម្ម ដូចជាកម្មវិធីកាយឫទ្ធិ កម្មវិធីយុវជន កម្មវិធីសិល្បៈ សិក្ខាសាលា... យើងជាយុវជនយុវនារីយើងយកចិត្តទុកដាក់ដើម្បីចូលរួម។ យើងជាយុវជនយុវនារី ឲ្យយើងធ្វើជាកីឡាកររបស់ព្រះជាម្ចាស់ ដែលបង្ហាញកម្លាំងដើម្បីកសាងព្រះសហគមន៍យើង។ រួមគ្នា ឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីបម្រើព្រះសហគមន៍យើង ដោយមានសកម្មភាពជាមួយកូនក្មេង មានសកម្មភាពជាមួយយុវជន។

យើងជាយុវជន **តើយើងធ្វើអ្វីខ្លះសម្រាប់ព្រះសហគមន៍របស់យើង**? ដើម្បីឲ្យព្រះសហគមន៍នីមួយៗមានគ្រីស្តបរិស័ទសកម្មដែលចេះទទួលខុសត្រូវយ៉ាងច្បាស់លាស់។ ព្រះសហគមន៍ពោធិ៍ធំ ជាព្រះសហគមន៍កំណើតរបស់ព្រះសហគមន៍ភូមិភាគភ្នំពេញយើងម្យ៉ាង ដែលបន្តពីពញ្ញាឮគ្រីស្តបរិស័ទបានមកដល់ទីនេះ ពេលមានវត្តមានព្រះសហគមន៍នៅទីក្រុងភ្នំពេញ។ ព្រះសហគមន៍បានចាប់ផ្តើមជាមួយគ្រីស្តបរិស័ទខ្មែរនៅទីនេះ ទីនេះជាភូមិកំណើតរបស់មរណសាក្សីយើង មានលោកអភិបាល ឆ្មារ សាឡាស់ លោក ឆ្មារ សាឡឹម...។ ព្រះសហគមន៍របស់យើងបានប្រទានឲ្យមានលោកអភិបាល មានលោកបូជាចារ្យ សព្វថ្ងៃយើងមានលោកឪពុកលីចាំមើលជំនាន់ក្រោយនេះតើយើងមានបងប្រុសបងស្រី លោកបូជាចារ្យប៉ុន្មាននាក់ចេញពីទឹកដីរបស់យើងនៅទីនេះ។ យើងត្រូវការនឹកឃើញដល់បុព្វបុរសរបស់យើង ដែលបានកើតលើទឹកដីពោធិ៍ធំនេះ ដើម្បីឲ្យយើងរួមគ្នាអាចទៅជាព្រះសហគមន៍មួយពិសេសនៅក្នុងភូមិភាគភ្នំពេញ។ នេះអាស្រ័យលើយុវជនយុវនារីយើង ដោយស្តាប់សក្ខីភាពនៃជីវិតព្រះសហគមន៍យើងពីដើមដែលព្រះសហគមន៍នេះជាព្រះសហគមន៍ពិសេស។

ខ្ញុំសូមអធិដ្ឋាន ដើម្បីឲ្យយើងទាំងអស់ភ្ញាក់ស្មារតីថែមទៀត ដើម្បីឲ្យព្រះសហគមន៍របស់យើងមានស្នាដៃតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយទុកព្រះបន្ទូលដែលយើងស្ដាប់ថ្ងៃនេះ "**សូមមានចិត្តស្រឡាញ់ដូចព្រះបិតាមានព្រះហឫទ័យស្រឡាញ់យើង**"។ នេះជាគម្រោងការរបស់សម្ដេចប៉ាប សម្រាប់ព្រះសហគមន៍យើង យើងត្រូវការប្រមូលកម្លាំងយើងដើម្បីទៅមុខទៀត។ យើងជាព្រះសហគមន៍តែមួយ យើងមានវត្តមានព្រះជាម្ចាស់តែមួយ ជាមួយពោធិ៍ធំ ជាមួយក្តីកណ្ដាល ជាមួយតាស្គ ជាមួយក្រុមបងប្រុសឌីឡាសាល ឲ្យយើងរួមគ្នាអាចកសាងព្រះហឫទ័យព្រះជាម្ចាស់នៅលើទឹកដីយើង ជាជីវិតដែលព្រះជាម្ចាស់ប្រទានសម្រាប់ព្រះសហគមន៍យើង។ អាម៉ែន។